ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ៣០៣ ឯក ប.ស្ថ

# ប្រកាស
## ស្តីពី
## បមាណីយមេត្រីភាពបរិស្ថាន

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ករម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការលើកទឹកចិត្តក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បកចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន



អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

# សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងជំរុញការអនុវត្ត និងលើកទឹកចិត្តចំពោះការចូលរួមជាសាធារណៈ រាល់សកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន សំដៅលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងដល់ប្រជាពលរដ្ឋគ្រប់រូបនិងគ្រប់ជំនាន់។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ និងសូចនាករសម្រាប់ការវាយតម្លៃគុណវុឌ្ឍិមេត្រីភាពបរិស្ថានរូបវន្តបុគ្គល និងនីតិបុគ្គល និងកំណត់កម្រៃសេវាវាយតម្លៃប្រតិបត្តិមេត្រីភាពបរិស្ថាន ដោយអនុលោមតាមអនុក្រឹត្យ លេខ៦០ អ.ន.ក្រ.បស្ត ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការលើកទឹកចិត្តក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពគ្របដណ្តប់លើរូបវន្តបុគ្គល និងនីតិបុគ្គល ដែលបានអនុវត្តសកម្មភាពផ្ដើមនៃមេត្រីភាពបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះមាន៖

ក. **មេត្រីភាពបរិស្ថាន** សំដៅលើការអនុវត្តច្បាប់ ផលិតកម្ម សេវាកម្ម និងបច្ចេកវិទ្យាដែលទ្រទ្រង់ដល់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងការរស់នៅដោយចីរភាព។

ខ. **បមាណីយមេត្រីភាពបរិស្ថាន** សំដៅដល់បទដ្ឋានបច្ចេកទេសសម្រាប់កំណត់លក្ខណៈវិនិច្ឆ័យ និងសូចនាករ ដែលត្រូវយកមកវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន។

គ. **រូបវន្តបុគ្គល** សំដៅដល់បុគ្គលម្នាក់ៗក្នុងវិស័យសាធារណៈ វិស័យឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សហគមន៍ រួមទាំងពលរដ្ឋទូទៅ ដែលមានគំនិតច្នៃប្រឌិតបរិស្ថានខ្ពស់ និងចូលរួមប្រតិបត្តិមេត្រីភាពបរិស្ថាន។

ឃ. **នីតិបុគ្គល** សំដៅដល់ស្ថាប័នសាធារណៈ ស្ថាប័នឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សហគមន៍ ដែលមានគំនិតច្នៃប្រឌិតបរិស្ថានខ្ពស់ និងចូលរួមប្រតិបត្តិមេត្រីភាពបរិស្ថាន។

ង. **គុណវុឌ្ឍិ** សំដៅលើលក្ខណៈសម្បត្តិ ទាក់ទងនឹងការអនុវត្ត ឬបទពិសោធន៍ ដែលឆ្លើយតបទៅនឹងតម្រូវការនៃការជ្រើសរើស និងការវាយតម្លៃការប្រតិបត្តិមេត្រីភាពបរិស្ថាន។

ច. **លក្ខណៈវិនិច្ឆ័យ** សំដៅដល់បទដ្ឋានបច្ចេកទេស សម្រាប់វាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន។

ឆ. **សូចនាករ** សំដៅលើការកំណត់ទៅលើបរិមាណ ឬគុណភាព ដែលត្រូវបានបង្កើតឡើងសម្រាប់វាស់វែង និងប្រៀបធៀបសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន។

**ប្រការ៥.-**

គោលការណ៍វាយតម្លៃការប្រតិបត្តិមេត្រីភាពបរិស្ថានត្រូវកំណត់តាមលក្ខណៈវិនិច្ឆ័យ និងសូចនាករ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ ស្តីពីលក្ខណៈវិនិច្ឆ័យ និងសូចនាករគោល សម្រាប់ការវាយតម្លៃគុណវុឌ្ឍិមេត្រីភាពបរិស្ថានរូបវន្តបុគ្គល និងនីតិបុគល។

**ប្រការ៦.-**

នីតិវិធីក្នុងការវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថានមាន ៦ដំណាក់កាលៈ

១. ទទួលពាក្យស្នើសុំវាយតម្លៃប្រតិបត្តិមេត្រីភាពបរិស្ថាន

២. ពិនិត្យពាក្យស្នើសុំ និងឯកសារពាក់ព័ន្ធ

៣. ពិនិត្យវាយតម្លៃគុណវុឌ្ឍិបឋម

៤. ចុះវាយតម្លៃតាមទីតាំងប្រតិបត្តិករផ្ទាល់

៥. រៀបចំរបាយការណ៍វាយតម្លៃគុណវុឌ្ឍិប្រតិបត្តិករពេញលេញ ដើម្បីជូនគណៈកម្មការវាយតម្លៃគុណវុឌ្ឍិមេត្រីភាពបរិស្ថាន

៦. គណៈកម្មការវាយតម្លៃគុណវុឌ្ឍិមេត្រីភាពបរិស្ថានប្រជុំពិនិត្យគុណវុឌ្ឍិប្រតិបត្តិករ និងលើកសំណើជូនថ្នាក់ដឹកនាំសម្រេចផ្តល់រង្វាន់ លើកទឹកចិត្តមេត្រីភាពបរិស្ថាន។

ក្នុងករណីពិសេស គណៈកម្មការវាយតម្លៃគុណវុឌ្ឍិមេត្រីភាពបរិស្ថាន មានសិទ្ធិវាយតម្លៃលើរូបវន្តបុគ្គល និងនីតិបុគ្គល ដែលមានគំនិតច្នៃប្រឌិតបរិស្ថានខ្ពស់ និងចូលរួមប្រតិបត្តិមេត្រីភាពបរិស្ថានដោយមិនចាំបាច់ដាក់ពាក្យ ដើម្បីផ្តល់បណ្ណសរសើរ ។

នីតិវិធីក្នុងការវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន ប្រើប្រាស់រយៈពេលមិនលើសពី ២៨ថ្ងៃនៃថ្ងៃធ្វើការងារ។

**ប្រការ៧.-**

ការជ្រើសរើសរូបវន្តបុគ្គល និងនីតិបុគ្គល ត្រូវធ្វើឡើងតាមរយៈការវាយតម្លៃរបស់គណៈកម្មការវាយតម្លៃគុណវុឌ្ឍិមេត្រីភាពបរិស្ថាន (**គ.វ.ម.ប.**)។

**ប្រការ៨.-**

រូបវន្តបុគ្គល និងនីតិបុគ្គល ដូចមានចែងក្នុងប្រការ៧ ខាងលើ នឹងត្រូវទទួលការលើកទឹកចិត្តប្រតិបត្តិមេត្រីភាពបរិស្ថានទៅតាមប្រភេទរង្វាន់។

ប្រភេទរង្វាន់មេត្រីភាពបរិស្ថាន មានកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងបរិស្ថាន។

**ប្រការ៩.-**

តម្លៃសេវា នៃការវាយតម្លៃប្រតិបត្តិមេត្រីភាពបរិស្ថានជាបន្ទុករបស់ប្រតិបត្តិករ។

តម្លៃសេវានេះ មានចែងក្នុងឧបសម្ព័ន្ធទី២ ស្តីពីកម្រៃសេវាវាយតម្លៃប្រតិបត្តិមេត្រីភាពបរិស្ថាន។

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានរង្វាន់ និងលើកទឹកចិត្ត ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ១១ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ទីកន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «ដើម្បីជូនជ្រាប»
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## លក្ខណៈវិនិច្ឆ័យ និងសូចនាករគោល

## សម្រាប់ការវាយតម្លៃគុណវុឌ្ឍិមេត្រីភាពបរិស្ថានរូបវន្តបុគ្គល និងនីតិបុគ្គល

### ១. រូបវន្តបុគ្គល

| លក្ខណៈវិនិច្ឆ័យ / សូចនាករ | ពិន្ទុ |
|---|---|
| ១. លក្ខណៈសម្បត្តិបុគ្គល | |
| - មានអាកប្បកិរិយា និងអត្តចរិតល្អ | |
| - មានសីលធម៌ និងគុណធម៌សង្គម | |
| - មានទំនាក់ទំនងល្អនៅក្នុងសង្គម | |
| - មានសម្បទា និងស្មារតីល្អ | |
| - មានឥរិយាបថវិជ្ជមានចំពោះបរិស្ថាន | |
| ២. ចំណេះដឹងអំពីបរិស្ថាន | |
| - មានសញ្ញាបត្រ ឬសញ្ញាបត្រប្រហាក់ប្រហែលទាក់ទងវិស័យបរិស្ថាន | |
| - មានបទពិសោធន៍ការងារបរិស្ថាន | |
| - ធ្លាប់ទទួល ធ្លាប់ចូលរួមសិក្ខាសាលា សកម្មភាពបរិស្ថាន ឬវេទិកាផ្សព្វផ្សាយបរិស្ថាន | |
| - ចំណេះដឹងបរិស្ថាន ដែលទទួលបានពីស្វ័យសិក្សា ឬចំណេះផ្ទេរតគ្នា | |
| ៣. ការចែករំលែកចំណេះដឹង និងបទពិសោធន៍ | |
| - ចែករំលែកចំណេះដឹងមេត្រីភាពបរិស្ថានដល់សហគមន៍ | |
| - រៀបចំកម្មវិធីផ្សព្វផ្សាយអំពីមេត្រីភាពបរិស្ថាន | |
| - ផ្សព្វផ្សាយមេត្រីភាពបរិស្ថានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម | |
| - ចងក្រងសៀវភៅ ឯកសារគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការរស់នៅដោយចីរភាព | |
| - កៀរគរឱ្យមានការចូលរួមអនុវត្តសកម្មភាពបរិស្ថាន | |
| ៤. ការប្រតិបត្តិមេត្រីភាពបរិស្ថាន | |
| - បែងចែកសំរាមទៅតាមប្រភេទ វេចខ្ចប់ និងទុកដាក់បានត្រឹមត្រូវ | |
| - ចូលរួមកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកស្របតាមអនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិក | |
| - គាំទ្រ និងប្រើប្រាស់ផលិតផលបរិស្ថាន | |
| - ចូលរួមសន្សំសំចៃការប្រើប្រាស់ក្រដាស ទឹក និងថាមពលអគ្គិសនី | |
| - ប្រើប្រាស់ថាមពលកកើតឡើងវិញ | |
| - ចូលរួមថែរក្សាអនាម័យបរិស្ថានតាមទីសាធារណៈ | |
| - មិនបង្កឱ្យមានផលប៉ះពាល់ដល់គុណភាពខ្យល់ និងការរំខានដោយសំឡេង | |
| - ប្រើប្រាស់សម្ភារផលិតពីវត្ថុធាតុដើមធម្មជាតិ | |
| - ប្រើប្រាស់ផលិតផល និងសម្ភារឡើងវិញ | |

| | |
|---|---|
| - ចូលរួមកែច្នៃផលិតផល និងសម្ភារចាស់ៗ | |
| - កែច្នៃកាកសំណល់សរីរាង្គធ្វើជាជីកំប៉ុស្ត | |
| - ចូលរួមប្រើប្រាស់ផលិតផលផ្សំពីវត្ថុធាតុដើមកកើតឡើងវិញ | |
| - ចូលរួមដាំដើមឈើ ថែរក្សា ការពារ និងអភិរក្សធនធានធម្មជាតិ | |
| - ចូលរួមអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី | |
| **៥. បទពិសោធន៍ការងារ និងទេពកោសល្យបរិស្ថាន** | |
| - មានគំនិតច្នៃប្រឌិតបរិស្ថានខ្ពស់ | |
| - បង្កើត ឬប្រើប្រាស់បច្ចេកវិទ្យាដែលទ្រទ្រង់បរិស្ថាន | |
| - មានការអនុវត្តល្អលើកកម្ពស់មេត្រីភាពបរិស្ថាន | |
| **៦. ប្រតិបត្តិផល និងគុណផលការងារមេត្រីភាពបរិស្ថាន** | |
| - ប្រសិទ្ធភាពនៃផលិតផល ឬសម្ភារ | |
| - គុណភាពនៃផលិតផល ឬសម្ភារ | |
| **៧.ការប្រតិបត្តិតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងបរិស្ថាន** | |
| - គោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបរិស្ថាន | |
| - អនុវត្តតាមប្រកាស បទបញ្ជា និងសារាចរណែនាំស្តីពីបរិស្ថាន | |
| - ផ្សព្វផ្សាយបន្តអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបរិស្ថាន | |

សម្គាល់៖ ការលើកទឹកចិត្តដល់រូបវន្តបុគ្គលប្រតិបត្តិមេត្រីភាពបរិស្ថាន ត្រូវបានវាយតម្លៃគុណវុឌ្ឍិ និង កំណត់ពិន្ទុលើសពី ៥០% នឹងត្រូវទទួលបានបណ្ណសរសើរមេត្រីភាពបរិស្ថាន។

| ៦. ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបរិស្ថាន | |
|---|---|
| - គោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបរិស្ថាន | |
| - អនុវត្តតាមប្រកាស បទបញ្ជា និងសារាចរណែនាំស្តីពីបរិស្ថាន | |
| - ផ្សព្វផ្សាយបន្តអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបរិស្ថាន | |
| - សហការជាមួយក្រសួង មន្ទីរបរិស្ថាន ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបរិស្ថាន | |

**សម្គាល់៖** ការលើកទឹកចិត្តដល់នីតិបុគ្គលប្រតិបត្តិមេត្រីភាពបរិស្ថាន ត្រូវបានវាយតម្លៃគុណវុឌ្ឍិ និងកំណត់ពិន្ទុលើសពី ៦០% នឹងត្រូវទទួលបានវិញ្ញាបនបត្រមេត្រីភាពបរិស្ថាន។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងបរិស្ថាន

## ២. នីតិបុគ្គល

| លក្ខណៈវិនិច្ឆ័យ / សូចនាករ | ពិន្ទុ |
|---|---|
| **១. ចក្ខុវិស័យបរិស្ថាន** | |
| - គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសកម្មភាព ស្ដីពីបរិស្ថាន | |
| - ផែនការអប់រំ និងអភិវឌ្ឍន៍ធនធានមនុស្សអំពីបរិស្ថាន | |
| - កម្មវិធីត្រួតពិនិត្យសកម្មភាពអនុវត្តការគ្រប់គ្រងបរិស្ថាន | |
| - កញ្ចប់ថវិកាអនុវត្តសកម្មភាពបរិស្ថាន | |
| - មធ្យោបាយ សម្ភារសម្រាប់អនុវត្តន៍ និងចូលរួមសកម្មភាពបរិស្ថាន | |
| **២. ហេដ្ឋារចនាសម្ព័ន្ធ** | |
| - ទីតាំង និងអគាររៀបចំសាងសង់ស្របតាមស្តង់ដាបច្ចេកទេសសំណង់ | |
| - អគារដែលមានបញ្ចូលស្ថាបត្យកម្មខ្មែរ | |
| - អគារមានមេត្រីភាពបរិស្ថាន | |
| **៣. ប្រតិបត្តិមេត្រីភាពបរិស្ថាន** | |
| - ការគ្រប់គ្រងសំណល់រឹង រាវ និងសារធាតុគីមីគ្រោះថ្នាក់ស្របតាមបច្ចេកទេសបរិស្ថាន | |
| - ចូលរួមអនុវត្តតាមគោលការណ៍ ៣Rs ក្នុងការគ្រប់គ្រងប្លាស្ទិក | |
| - ប្រើប្រាស់សម្ភារ ឧបករណ៍ដែលជាផលិតផលផ្សំពីវត្ថុធាតុដើមករកើតឡើងវិញ | |
| - ចូលរួមកែច្នៃ និងប្រើប្រាស់ផលិតផលឡើងវិញ | |
| - ការប្រើប្រាស់ទឹក និងថាមពលប្រកបដោយប្រសិទ្ធភាព | |
| - លើកទឹកចិត្តការអនុវត្តកម្មវិធីលទ្ធកម្មបៃតង | |
| - បង្កើត ឬប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន | |
| - ចូលរួមសកម្មភាពសង្គមនានាដែលទ្រទ្រង់បរិស្ថាន និងធនធានធម្មជាតិ | |
| **៤. លំហបៃតង (ក្រៅអគារ)** | |
| - ទីធ្លា តំបន់បៃតង សួនជីវៈចម្រុះ | |
| - មានផែនការការពារធនធានធម្មជាតិដែលមានស្រាប់ | |
| - ចូលរួមអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី | |
| **៥. ការបញ្ជ្រាបចំណេះដឹងបរិស្ថាន** | |
| - ផ្សព្វផ្សាយឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពស្ដីពីបរិស្ថាន | |
| - ចែករំលែកចំណេះដឹងមេត្រីភាពបរិស្ថានដល់សាធារណជន | |
| - រៀបចំកម្មវិធីបណ្តុះបណ្តាល ផ្សព្វផ្សាយអំពីមេត្រីភាពបរិស្ថាន | |
| - មានការផលិតឯកសារ វីដេអូ និងរូបភាពទាក់ទងនឹងមេត្រីភាពបរិស្ថាន | |
| - កៀរគរឱ្យមានការចូលរួមអនុវត្តសកម្មភាពបរិស្ថាន | |
| - កិច្ចសហការជាមួយក្រសួង ស្ថាប័ន វិស័យឯកជន គ្រឹះស្ថានអប់រំ សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល លើកិច្ចការបរិស្ថាន | |

# ឧបសម្ព័ន្ធទី២
# តម្រែសេវាវាយតម្លៃប្រតិបត្តិមេត្រីភាពបរិស្ថាន

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃឯកតា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| សេវាវាយតម្លៃប្រតិបត្តិមេត្រីភាពបរិស្ថាន (តាមការស្នើសុំ) | | | | |
| ១ | តំបន់សេដ្ឋកិច្ចពិសេស | ៤ ០០០ ០០០ | ២៨ថ្ងៃ | ២ឆ្នាំ |
| ២ | រោងចក្រ បុរីលំនៅដ្ឋាន ធនាគារ | ២ ០០០ ០០០ | ២៨ថ្ងៃ | ២ឆ្នាំ |
| ៣ | ក្រុមហ៊ុន អគារពាណិជ្ជកម្ម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សណ្ឋាគារ ផ្ទះសំណាក់ មណ្ឌលកំសាន្ត រមណីយដ្ឋាន បឹងហ្គាឡូ កោដនីយដ្ឋាន | ១ ០០០ ០០០ | ២៨ថ្ងៃ | ២ឆ្នាំ |
| ៤ | សហគ្រាស អាជីវកម្ម សេវាកម្មឯកជន គ្រឹះស្ថានសិក្សាឯកជន | ៥០០ ០០០ | ២៨ថ្ងៃ | ២ឆ្នាំ |